00416849

D130/9/21

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

**ការចោទប្រកាន់ព្រះរាជអាជ្ញាខ្មែរ និងការចោទអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ**

**សំណុំរឿងព្រហ្មទណ្ឌលេខ:** ០០២/១៩-០៩-២០០៧/អវតក/កសចស (អបជ ២៦)

**ចំពោះមុខ:**
ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម និយ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 18 / 12 / 2009
ម៉ោង (Time/Heure): 11:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A. Tuy

**កាលបរិច្ឆេទ:** ១៨ ខែធ្នូ ឆ្នាំ២០០៩

---

**សាធារណៈ**

**សាលដីកាលើភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ សហចៅក្រមស៊ើបអង្កេតសម្រេចអំពីការប្រើប្រាស់ចម្លើយដែលបានមក ឬដែលអាចបានមក ដោយសារការធ្វើទារុណកម្ម**

---

**<u>សហព្រះរាជអាជ្ញា</u>**
ជា លាង
Andrew CAYLEY
William SMITH
យ៉េត ចរិយា

**<u>ជនត្រូវចោទ</u>**
អៀង ធីរិទ្ធ

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 18 / 12 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A. Tuy

អង្គបុរេជំនុំជម្រះ * E.C.C.C * C.E.T.C * PRE-TRIAL CHAMBER * CHAMBRE PRÉLIMINAIRE

០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ២៦)

លេខ/N. D130/9/21

សេង ប៊ុនឃាង

Vincent de WILDE d'ESTMAEL

**<u>មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**

ហុង គីមសួន

ឡោ ជុនធី

នី ចាន់ដា

គង់ ពិសី

យុង ផានិត

គីម ម៉េងឃី

ម៉ុច សុវណ្ណារី

ស៊ិន សុវ៉ន

Silke STUDZINSKY
Martine JACQUIN
Philippe CANONNE
Pierre Olivier SUR
Elizabeth RABESANDRATANA
Olivier BAHOUGNE
David BLACKMAN
Annie DELAHAIE
Fabienne TRUSSES-NAPROUS
Patrick BEAUDOIN
Marie GUIRAUD
LYMA NGUYEN

**<u>ដើមបណ្តឹងរដ្ឋប្បវេណីដែលគ្មាន</u>**

**<u>មេធាវីតំណាង</u>**

**<u>សហមេធាវីការពារជនត្រូវចោទ</u>**

ផាត់ ពៅស៊ាង

Diana ELLIS

PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“**អ.វ.ត.ក**”) បានទទួល “បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ [សហចៅក្រមស៊ើបអង្កេត] សម្រេចអំពីការប្រើប្រាស់ចម្លើយដែលបានមក ឬដែលអាចបានមកដោយសារការធ្វើទារុណកម្ម” ដែលបានដាក់ដោយសហមេធាវីការពារក្តីជនត្រូវចោទ អៀង ធីរិទ្ធ កាលពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៩ (“បណ្តឹងឧទ្ធរណ៍”)[១]។

## I- **ប្រវត្តិនីតិវិធី**

១. នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៩ សហមេធាវីការពារក្តី អៀង ធីរិទ្ធ (“សហមេធាវីការពារក្តី”) បានដាក់សំណើជូនសហចៅក្រមស៊ើបអង្កេត សុំឱ្យដកភស្តុតាងដែលបានមកដោយសារការធ្វើទារុណកម្មចេញពីសំណុំរឿងលេខ០០២ (សំណើសុំ)[២]។ សហមេធាវីការពារក្តីបានស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតសម្រេចថា ភស្តុតាងនេះមិនអាចទទួលយកបាន ក្រៅតែពីការបង្ហាញថា ចម្លើយដោយសារការធ្វើទារុណកម្មត្រូវបានធ្វើឡើង និងគ្រាន់តែដើម្បីប្រឆាំងនឹងអ្នកធ្វើទារុណកម្មដែលបានចោទប្រកាន់ប៉ុណ្ណោះ។

---

[១] បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចអំពីការប្រើប្រាស់ចម្លើយដែលបានមក ឬអាចបានមកដោយការធ្វើទារុណកម្ម ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៩ ឯកសារ D130/9/6 (“បណ្តឹងឧទ្ធរណ៍”)។

[២] សំណើសុំបដិសេធភស្តុតាងដែលបានមកដោយការធ្វើទារុណកម្មរបស់សហមេធាវីការពារក្តី ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៩ ឯកសារ D130 (“សំណើសុំ”)។

២. នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាបានដាក់ចម្លើយតបទៅនឹងសំណើរបស់សហមេធាវីការពារក្តីសុំឱ្យដកចេញភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម[៣]។ សហព្រះរាជអាជ្ញាបានស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតធ្វើការបដិសេធលើសំណើសុំទាំងមូល សុំឱ្យរក្សាភស្តុតាងដែលមានវិវាទទុកក្នុងសំណុំរឿងលេខ០០២ និងសុំឱ្យបន្តទទួលយកភស្តុតាងបែបនេះទៀត នាពេលអនាគត។

៣. នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ សហមេធាវីការពារក្តីបានដាក់ "សារណាតបរបស់សហមេធាវីការពារក្តីទៅនឹងចម្លើយតបរបស់ "សហព្រះរាជអាជ្ញា" ទៅនឹងសំណើសុំឱ្យដកចេញនូវភស្តុតាងដែលបានមកពីការធ្វើទារុណកម្មរបស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ"[៤]។ នៅក្នុងឯកសារនេះ សហមេធាវីការពារក្តីបានរក្សានូវសំណើសុំរបស់ខ្លួន និងបានស្នើឱ្យដកឯកសារបន្ថែមចេញពីសំណុំរឿង។

៤. នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩ សហចៅក្រមស៊ើបអង្កេតបានចេញ "ដីកាសម្រេចលើការប្រើប្រាស់ភស្តុតាងដែលបានមក ឬដែលអាចបានមកដោយសារការធ្វើទារុណកម្ម" (ដីកា) ដែលបានបដិសេធសំណើសុំរបស់សហមេធាវីការពារក្តី[៥]។

៥. នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៩ សហមេធាវីការពារក្តីបានដាក់ "សេចក្តីជូនដំណឹងស្តីពីបណ្តឹងឧទ្ធរណ៍" ប្រឆាំងនឹងដីកា[៦]។

---

[៣] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើសុំបដិសេធភស្តុតាងដែលបានមកដោយការធ្វើទារុណកម្មរបស់សហមេធាវីការពារក្តីជនត្រូវចោទ អៀង ធីរិទ្ធ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៩ ឯកសារ D130/៥។

[៤] ចម្លើយតបរបស់សហមេធាវីការពារក្តីទៅនឹង "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើសុំបដិសេធភស្តុតាង ដែលបានមកដោយការធ្វើទារុណកម្មរបស់សហមេធាវីការពារក្តី ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ ឯកសារ D130/៦។

[៥] ដីកាសម្រេចអំពីការប្រើប្រាស់ចម្លើយដែលបានមក ឬអាចបានមកដោយការធ្វើទារុណកម្ម ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០០៩ ឯកសារ D130/8 ("ដីកា")។

00416853



៦. នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៩ សហមេធាវីការពារក្តីបានដាក់ "សំណើបន្ទាន់របស់សហមេធាវីការពារក្តីសុំពន្យារពេលវេលាកំណត់ក្នុងការដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង "ដីកាសម្រេចលើការប្រើប្រាស់ចម្លើយដែលបានមក ឬដែលអាចបានមកដោយការធ្វើទារុណកម្ម"[៧]។ អង្គបុរេជំនុំជម្រះបានយល់ព្រមពន្យារពេលវេលាក្នុងការដាក់បណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី រហូតដល់ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៩[៨]។

៧. នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៩ សហមេធាវីការពារក្តី អៀង ធីរិទ្ធ បានដាក់បណ្តឹងឧទ្ធរណ៍។

៨. នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាបានដាក់ "សំណើបន្ទាន់សុំពន្យារពេលវេលាក្នុងការដាក់ចម្លើយតបរួមទៅនឹងបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ អៀង ធីរិទ្ធ និង ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចលើការប្រើប្រាស់ចម្លើយដែលបានមក ឬដែលអាចបានមកដោយការធ្វើ

---

[៦] សេចក្តីជូនដំណឹងរបស់សហមេធាវីការពារក្តីជនត្រូវចោទ អៀង ធីរិទ្ធ អំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចអំពីការប្រើប្រាស់ចម្លើយដែលបានមក ឬអាចបានមកដោយការធ្វើទារុណកម្ម ចុះថ្ងៃទី[illegible] ខែកក្កដា ឆ្នាំ២០០៩ ឯកសារ D130/9។

[៧] សំណើបន្ទាន់របស់សហមេធាវីការពារក្តីសុំពន្យារពេលវេលាកំណត់ក្នុងការដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង "ដីកាសម្រេចលើការប្រើប្រាស់ចម្លើយដែលបានមក ឬដែលអាចបានមកដោយការធ្វើទារុណកម្ម" ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៩ ឯកសារ D130/9/1។

[៨] សេចក្តីសម្រេចលើសំណើរបស់សហមេធាវីការពារក្តីសុំពន្យារពេលវេលាកំណត់ក្នុងការដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង "ដីកាសម្រេចលើការប្រើប្រាស់ចម្លើយដែលបានមក ឬដែលអាចបានមកដោយការធ្វើទារុណកម្ម ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ឯកសារ D130/9/2។

ទារុណកម្ម"[៩]។ អង្គបុរេជំនុំជម្រះ បានយល់ព្រមពន្យារពេលវេលាក្នុងការដាក់ចម្លើយតបរបស់សហព្រះរាជអាជ្ញា រហូតដល់ ថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩[១០]។

៩. នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាបានដាក់ "ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ អៀង ធីរិទ្ធ និង ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចលើការប្រើប្រាស់ចម្លើយដែលបានមក ឬដែលអាចបានមកដោយការធ្វើទារុណកម្ម" ("ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា")[១១]។ នៅក្នុងចម្លើយតបរបស់ខ្លួន សហព្រះរាជអាជ្ញាបានលើកឡើងនូវបញ្ហានានា ដែលពាក់ព័ន្ធនឹងភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍[១២]។

១០. នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៩ អង្គបុរេជំនុំជម្រះបានណែនាំឱ្យសហមេធាវីការពារក្តីបញ្ចេញនូវទស្សនៈយល់ឃើញរបស់ខ្លួន ពាក់ព័ន្ធនឹងបញ្ហានៃភាពអាចទទួលយកបានដែលបានលើកឡើងដោយសហព្រះរាជអាជ្ញានៅក្នុងចម្លើយតបរួមរបស់ខ្លួន ("សេចក្តីណែនាំរបស់អង្គបុរេជំនុំជម្រះ")[១៣]។

---

[៩] សំណើបន្ទាន់របស់សហព្រះរាជអាជ្ញាសុំពន្យារពេលវេលាកំណត់ ក្នុងការដាក់ចម្លើយតបរួមទៅនឹងបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ អៀង ធីរិទ្ធ និង ខៀវ សំផន ប្រឆាំងនឹង "ដីកាសម្រេចលើការប្រើប្រាស់ចម្លើយដែលបានមក ឬដែលអាចបានមកដោយការធ្វើទារុណកម្ម ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩ ឯកសារ D130/9/7។

[១០] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំពន្យារពេលវេលាកំណត់ក្នុងការដាក់ចម្លើយតបរួមទៅនឹងបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹង "ដីកាសម្រេចលើការប្រើប្រាស់ចម្លើយដែលបានមក ឬដែលអាចបានមក ដោយការធ្វើទារុណកម្ម ចុះថ្ងៃ ទី១៧ ខែកញ្ញា ឆ្នាំ២០០៩ ឯកសារ D130/9/8។

[១១] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ជន ត្រូវចោទ អៀង ធីរិទ្ធ និង ខៀវ សំផន ប្រឆាំងនឹង "ដីកាសម្រេចលើការប្រើប្រាស់ចម្លើយដែលបានមក ឬដែលអាចបានមក ដោយការធ្វើទារុណកម្ម ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩ ឯកសារ D130/9/13 ("ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា")។

[១២] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌទី៧។

[១៣] សេចក្តីណែនាំដល់សហមេធាវីការពារក្តីឱ្យបង្ហាញមតិយោបល់របស់ខ្លួន ពាក់ព័ន្ធនឹងបញ្ហានៃភាពអាចទទួលយកបានដែលបានលើកឡើងដោយសហព្រះរាជអាជ្ញានៅក្នុងចម្លើយតបរួមរបស់ខ្លួនទៅនឹងបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៩ ("សេចក្តីណែនាំរបស់អង្គបុរេជំនុំជម្រះ") ឯកសារ D130/9/16។

នៅថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០០៩ សហមេធាវីការពារក្ដីបានលើកឡើងនូវមតិយោបល់របស់ខ្លួន យោងតាមសេចក្ដីណែនាំរបស់អង្គបុរេជំនុំជម្រះ[១៤]។

## II. សេចក្ដីសន្និដ្ឋានរបស់ភាគីនានា

១១. នៅក្នុងបណ្ដឹងឧទ្ធរណ៍របស់ខ្លួន សហមេធាវីការពារក្ដីជនត្រូវចោទបានស្នើឲ្យអង្គបុរេជំនុំជម្រះ (i) មោឃៈភាពដីកា (ii) ស្នើឲ្យសហចៅក្រមស៊ើបអង្កេត "សម្រេចថាមិនអាចទទួលយកបាននូវភស្តុតាងណាមួយ ឬក៏សម្ភារៈណាផ្សេងទៀតដែលបានមក ឬដែលអាចបានមកដោយការប្រើប្រាស់នូវទារុណកម្ម ក្រៅពីការបង្ហាញថា ចម្លើយមួយចំនួនត្រូវបានធ្វើឡើង ដោយសារការធ្វើទារុណកម្ម និងគ្រាន់តែដើម្បីប្រឆាំងនឹងអ្នកធ្វើទារុណកម្មដែលបានចោទប្រកាន់តែប៉ុណ្ណោះ [...] និង(iii) ស្នើឲ្យសហចៅក្រមស៊ើបអង្កេតទប់ស្កាត់ការប្រើប្រាស់ចម្លើយបែបនេះ តាមមធ្យោបាយផ្សេងទៀត"[១៥]។

១២. សហមេធាវីការពារក្ដីបានដាក់បណ្ដឹងឧទ្ធរណ៍ អនុលោមតាមវិធាន៥៥(១០) និង៧៤(៣)(ខ) នៃវិធានផ្ទៃក្នុង ព្រមទាំងពាក់ព័ន្ធជាមួយនឹងគោលការណ៍គ្រឹះនានាដែលមាននៅក្នុងវិធាន២១ នៃវិធានផ្ទៃក្នុង[១៦]។ សហមេធាវីការពារក្ដីលើកទឡ្ហីករណ៍ថា វិធាន៥៥(១០) នៃវិធានផ្ទៃក្នុង គួរតែត្រូវបានបកស្រាយថា វិធាននេះ "ចែងអំពីសិទ្ធិក្នុងការធ្វើបណ្ដឹងឧទ្ធរណ៍បន្ទាន់បង្កប្រឆាំងនឹងការបដិសេធ

---

[១៤] មតិយោបល់របស់សហមេធាវីការពារក្ដីជនត្រូវចោទ អៀង ធីរិទ្ធ លើ "សេចក្ដីណែនាំដល់សហមេធាវីការពារក្ដីឲ្យបញ្ជូនមតិយោបល់របស់ខ្លួនពាក់ព័ន្ធនឹងបញ្ហានៃភាពអាចទទួលយកបាន ដែលបានលើកឡើងដោយសហព្រះរាជអាជ្ញានៅក្នុងចម្លើយតបរួមរបស់ខ្លួនទៅនឹងបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ D130/9/17។ ("សារណារបស់សហមេធាវីការពារក្ដីអំពីបញ្ហាភាពអាចទទួលយកបាន")។

[១៥] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌទី ១២៤។

[១៦] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌទី ១០។

លើសំណើសុំទូទៅទាំងពីរ និងសំណើសុំបំពេញកិច្ចស៊ើបសួរ"[១៧]។ ទោះបីជាសហមេធាវីការពារក្តីទទួលស្គាល់វិធាន៧៤(៣)(ខ) នៃវិធានផ្ទៃក្នុង ដែលបានកំណត់ព្រំដែននៃសិទ្ធិក្នុងការធ្វើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំ ដើម្បីបង្គាប់ឲ្យមានការបដិសេធមិនបំពេញកិច្ចស៊ើបសួរនោះ សហមេធាវីការពារក្តីលើកទឡ្ហីករណ៍ថា ដើម្បីជៀសវាងនូវភាពមិនស្របគ្នា វិធាន៥៥(១០) នៃវិធានផ្ទៃក្នុងគួរមានអធិកភាព យោងតាម*គោលការណ៍នៃសច្ចធារណ៍នៃនិរទោស* (*in dubio pro reo*)[១៨]។ សហមេធាវីការពារក្តីលើកឡើងថា មូលដ្ឋានផ្សេងទៀតសម្រាប់ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍គឺ: ១) ការបំពានលើការកាត់សេចក្តីដោយយុត្តិធម៌ និង ២) ការប្រព្រឹត្តិទៅដ៏ឆាប់រហ័សនៃកិច្ចដំណើរការនីតិវិធី[១៩]។

១៣. នៅក្នុងចម្លើយតបរួមរបស់ខ្លួន សហព្រះរាជអាជ្ញាបានស្នើឲ្យអង្គបុរេជំនុំជម្រះបដិសេធបណ្តឹងឧទ្ធរណ៍។ សហព្រះរាជអាជ្ញាលើកឡើងថា "[បណ្តឹងឧទ្ធរណ៍] មិនកើតឡើង ដោយសារការបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរ ដែលធ្វើដោយសហចៅក្រមស៊ើបអង្កេតនោះទេ ដូចនេះបណ្តឹងឧទ្ធរណ៍មិនអាចទទួលយកបានទេ"[២០]។ សហព្រះរាជអាជ្ញាបានលើកឡើងថែមទៀតថា "ប្រសិនបើបណ្តឹងឧទ្ធរណ៍ត្រូវបានចាត់ទុកថាជាសំណើសុំមោឃភាព ពេលនោះបណ្តឹងឧទ្ធរណ៍ទាំងនោះ មានកំហុសផ្នែកនីតិវិធី និងផ្នែកសារធាតុ។

១៤. នៅក្នុងសារណាតបរបស់ខ្លួនទៅនឹងសេចក្តីណែនាំរបស់អង្គបុរេជំនុំជម្រះ សហមេធាវីការពារក្តីបានយោងលើទឡ្ហីករណ៍របស់ខ្លួនដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍ និងបានលើកឡើង

---

[១៧] ការបកស្រាយរបស់សហមេធាវីការពារក្តីអំពីពាក្យ "សំណើសុំទូទៅ" របស់ខ្លួន គឺជា "ការ[illegible]ការដឹកនាំកិច្ចស៊ើបសួរ" និងពាក្យ "សំណើសុំបំពេញកិច្ចស៊ើបសួរ" គឺជា "កិច្ចស៊ើបសួរដែលចាំ[illegible]ស៊ើបសួរ"។ សូមមើល បណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី ១២។

[១៨] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី ១៥។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ឃ្លាជាអក្សរឡាតាំងនេះ *in dubio pro reo* ត្រូវបានបកប្រែថា "នៅពេលមានមន្ទិលសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ"។

[១៩] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី ១៦ ដល់ ២២។

[២០] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌទី៧។

ថែមទៀតថា ទឡ្ហីករណ៍ដែលបានគូសបញ្ជាក់អំពីភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ គឺថា នៅពេលដែលបញ្ហានេះត្រូវបានដោះស្រាយដោយអង្គជំនុំជម្រះសាលាដំបូងនាពេលថ្មីៗនេះ "ភាពចម្រូងចម្រាសគ្នាជុំវិញការប្រើប្រាស់ភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម ត្រូវយកមកធ្វើការដោះស្រាយនៅដំណាក់កាលបុរេជំនុំជម្រះ ដើម្បីកំណត់សម្រេចអំពីដែនកំណត់នៃអំណាចផ្នែកស៊ើបអង្កេតរបស់ [សហចៅក្រមស៊ើបអង្កេត] ផងដែរ"[២១]។

## III. ច្បាប់ពាក់ព័ន្ធ

១៥. សេចក្តីយោងត្រូវបានធ្វើលើវិធាន២១, ៥៥(១០), ៧៣, ៧៤(៣) និង ៧៥ នៃវិធានផ្ទៃក្នុង។

## IV. ភាពអាចទទួលយកបាន

១៦. នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩ សហចៅក្រមស៊ើបអង្កេតបានចេញដីកា ដែលត្រូវបានជូនដំណឹងដល់ភាគីនានាកាលពីថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៩។ សហមេធាវីការពារក្តីជនត្រូវចោទបានដាក់សេចក្តីជូនដំណឹងស្តីពីបណ្តឹងឧទ្ធរណ៍ កាលពីថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៩។ សារណាបណ្តឹងឧទ្ធរណ៍ត្រូវបានដាក់កាលពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៩ យោងតាមការពន្យារពេលដែលបានអនុញ្ញាតឲ្យដោយអង្គបុរេជំនុំជម្រះ។

១៧. ការកំណត់សម្រេចថា តើអង្គបុរេជំនុំជម្រះមានយុត្តាធិការលើបណ្តឹងឧទ្ធរណ៍ដែរឬទេនោះ អង្គបុរេជំនុំជម្រះ ត្រូវចាប់ផ្តើមធ្វើការត្រួតពិនិត្យលើលក្ខណៈ នៃសំណើសុំរបស់សហមេធាវីការពារក្តីដែលពាក់ព័ន្ធ។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សហមេធាវីការពារក្តីបានលើកឡើងថា

---

[២១] សារណាតបរបស់សហមេធាវីការពារក្តីអំពីបញ្ហាភាពអាចទទួលយកបាន កថាខណ្ឌទី១០ និងទី១១ *សាលដីកាលើភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចអំពីការប្រើប្រាស់ចម្លើយដែលបានមក ឬអាចបានមកដោយការធ្វើទារុណកម្ម*

00416858



សំណើសុំចំពោះសហចៅក្រមស៊ើបអង្កេតអនុលោមតាមវិធាន៥៥(១០) នៃវិធានផ្ទៃក្នុង "ដែលចែងថា នៅក្នុងអំឡុងពេលស៊ើបអង្កេត ជនត្រូវចោទអាចស្នើឱ្យ [សហចៅក្រមស៊ើបអង្កេត] ចេញដីកាបែបនោះ នៅពេលដែលខ្លួនពិចារណាឃើញថា មានភាពចាំបាច់សម្រាប់ការដឹកនាំកិច្ចស៊ើបសួរ"[២២]។ នៅក្នុងសេចក្តីសន្និដ្ឋាននៃសំណើសុំ សហមេធាវីការពារក្តីបានស្នើឱ្យសហចៅក្រមស៊ើបអង្កេត:

(i) "ចាត់ទុកថាមិនអាចទទួលយកបាននូវភស្តុតាង ឬសម្ភារៈផ្សេងទៀត ដែលបានមក ឬដែលអាចបានមកដោយការប្រើប្រាស់ទារុណកម្ម [...]

(ii) ចៀសវាងការប្រើប្រាស់ចម្លើយបែបនេះតាមមធ្យោបាយផ្សេងទៀត[...]"

១៨. បន្ទាប់ពីបានពិចារណាអំពីគោលបំណងនៃសំណើសុំរួចមក អង្គបុរេជំនុំជម្រះសង្កេតឃើញថា សំណើសុំមិនមែនជា"សំណើសុំបំពេញកិច្ចស៊ើបសួរ"នោះទេ នៅក្នុងក្របខណ្ឌនៃវិធាន៧៤(៣)(ខ) នៃវិធានផ្ទៃក្នុង និងដូចដែលបានកំណត់ដោយអង្គបុរេជំនុំជម្រះ នៅក្នុងសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ស្តីពីការបកប្រែភាសារបស់ជនត្រូវចោទ ខៀវ សំផន[២៣] ថា ជាសំណើសុំបំពេញកិច្ចស៊ើបសួរដែលត្រូវបំពេញដោយសហចៅក្រមស៊ើបអង្កេត ឬទៅលើការផ្ទេរអំណាច ដោយអ្នកស៊ើបអង្កេតអ.វ.ត.ក ឬនគរបាលយុត្តិធម៌ ដោយមានគោលបំណងប្រមូលផ្តុំនូវព័ត៌មានដែលនាំឱ្យរកឃើញនូវការពិត។

១៩. អង្គបុរេជំនុំជម្រះសង្កេតឃើញថែមទៀតថា លទ្ធភាពក្នុងការប្តឹងឧទ្ធរណ៍ ដែលផ្តើមចេញពីដីការបស់សហចៅក្រមស៊ើបអង្កេត មានដែនកំណត់សម្រាប់ជនត្រូវចោទ ចំណែកឯសហព្រះរាជ

---

[២២] សំណើសុំ កថាខណ្ឌទី៣។

[២៣] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើសំណើសុំបាននូវការបកប្រែភាសារបស់ភាគីនានា ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៩ កថាខណ្ឌទី២៨ ឯកសារ A190/I/20។

អាជ្ញាអាចប្តឹងឧទ្ធរណ៍លើគ្រប់ដីកាទាំងអស់[២៤]។ ភាពមិនស៊ីសង្វាក់គ្នាដែលអាចកើតចេញមកពីលទ្ធភាពទូទៅក្នុងការប្តឹងឧទ្ធរណ៍ដែលបានលើកឡើង ស្របតាមវិធាន៥៥(១០)នៃវិធានផ្ទៃក្នុង និងលទ្ធភាព ដែលមានដែនកំណត់ក្នុងការប្តឹងឧទ្ធរណ៍សម្រាប់ជនត្រូវចោទ ស្របតាមវិធាន៧៤(៣)(ខ) មិនអាចនាំឱ្យមានសេចក្តីសន្និដ្ឋាន ដូចដែលបានធ្វើដោយសហមេធាវីការពារក្តីស្តីពីភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍នេះឡើយ។

២០. អង្គបុរេជំនុំជម្រះបានកត់សម្គាល់ឃើញថែមទៀតថា ជាទូទៅ អង្គបុរេជំនុំជម្រះគ្មានយុត្តាធិការក្នុងការពិនិត្យមើលឡើងវិញនូវបញ្ហានានា ដែលពាក់ព័ន្ធនឹងភាពអាចទទួលយកបាននៃភស្តុតាងដូចនេះទេ។ យោងតាមវិធានផ្ទៃក្នុង បញ្ហានៃភាពអាចទទួលយកបាននៃភស្តុតាងកើតឡើងនៅដំណាក់កាលជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធីរឿងក្តីព្រហ្មទណ្ឌ[២៥]។ ស្រដៀងគ្នានេះដែរ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាបានចែងអំពីបទដ្ឋានតិចតួចណាស់ ពាក់ព័ន្ធនឹងភាពអាចទទួលយកបាននៃភស្តុតាង ហើយបទដ្ឋានទាំងអស់នេះមានការពាក់ព័ន្ធនឹងដំណាក់កាលជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធី នៅពេលដែលចៅក្រមជំនុំជម្រះត្រូវបានផ្តល់ឱ្យនូវឆន្ទានុសិទ្ធិទូលំទូលាយ នៅក្នុងការសម្រេចថាតើ ទទួលយកនូវភស្តុតាងដែរឬទេ[២៦]។

២១. អង្គបុរេជំនុំជម្រះយល់ឃើញថា តាមមូលហេតុទាំងអស់នេះ បណ្តឹងឧទ្ធរណ៍មិនអាចត្រូវប្រកាសថា អាចទទួលយកបាននោះទេ នៅពេលដែលអនុវត្តវិធាន៥៥ និង ៧៤ នៃវិធានផ្ទៃក្នុងនោះ។

២២. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា វិធាន៧៦នៃវិធានផ្ទៃក្នុង បានចែងអំពីឱកាសសម្រាប់ភាគីធ្វើការស្នើសុំសហចៅក្រមស៊ើបអង្កេតឱ្យមោឃៈភាពកិច្ចស៊ើបសួរ។ គេបានកត់សម្គាល់ឃើញថែមទៀតថា បទបញ្ញត្តិនេះមានបំណងបដិសេធភស្តុតាងទាំងមូល។ សំណើសុំដែលបានធ្វើឡើងចំពោះសហចៅក្រមស៊ើបអង្កេត មា នបំណងបដិសេធតែផ្នែកខ្លះ ដែលភស្តុតាងត្រូវបានប្រើប្រាស់

---

[២៤] វិធាន ៧៤(២) នៃវិធានផ្ទៃក្នុង។

[២៥] វិធាន ៨៧ នៃវិធានផ្ទៃក្នុង។

[២៦] មាត្រា៣២១ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

ផ្សេងពីការអនុញ្ញាតស្របតាមអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ("CAT") តែប៉ុណ្ណោះ។ ហេតុនេះហើយ ការលើកឡើងដែលធ្វើដោយសហព្រះរាជអាជ្ញាដែលថា នីតិវិធីនេះគួរតែត្រូវបានប្រើប្រាស់ដោយសហមេធាវីការពារក្ដីនោះ គ្មានមូលដ្ឋានច្បាប់នោះទេ។

២៣. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថែមទៀតថា សហមេធាវីការពារក្ដីសន្និដ្ឋានថា មូលដ្ឋានផ្សេងៗសម្រាប់ភាពអាចទទួលយកបាននៃបណ្ដឹងឧទ្ធរណ៍ គឺ: ១) ការបំពានលើការកាត់សេចក្ដីដោយយុត្តិធម៌ និង ២) ការប្រព្រឹត្តិទៅយ៉ាងឆាប់រហ័សនៃកិច្ចដំណើរការនីតិវិធី។

២៤. ពាក់ព័ន្ធនឹងបញ្ហានេះ វិធាន២១ នៃវិធានផ្ទៃក្នុង ចែងថា:

> "វិធាន២១ គោលការណ៍គ្រឹះ
>
> ១. ច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ វិធានផ្ទៃក្នុង សេចក្ដីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ និងកិច្ចព្រមព្រៀង។ ក្នុងបរិបទនេះ៖
>
> > ក-ដំណើរការនីតិវិធីក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ [...]
>
> ៤. ការសម្រេចសេចក្ដីលើការចោទប្រកាន់ចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញត្រូវធ្វើការជំនុំជម្រះក្នុងរយៈពេលមួយសមស្រប។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C * C.E.T.C

២៥. អង្គបុរេជំនុំជម្រះត្រូវពិនិត្យ ថាតើវិធាន២១នៃវិធានផ្ទៃក្នុង កំណត់លក្ខខណ្ឌថា វិធាននេះអនុម័តនូវការបកស្រាយកាន់តែទូលំទូលាយអំពីសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ ដើម្បីធានាថាកិច្ចដំណើរការនីតិវិធីមានភាពត្រឹមត្រូវ និងឆាប់រហ័សដែរឬទេ។

២៦. អង្គបុរេជំនុំជម្រះសង្កេតឃើញថា វិធានផ្ទៃក្នុងបានផ្តល់ដល់ជនត្រូវចោទនូវលទ្ធភាពក្នុងការជំទាស់ទៅនឹងភាពអាចទទួលយកបាននៃភស្តុតាងនៅក្នុងដំណាក់កាលសវនាការ។ សេចក្តីយោងត្រូវបានធ្វើលើវិធាន៨៧ នៃវិធានផ្ទៃក្នុង[២៧]។

២៧. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថែមទៀតថា នីតិវិធីដែលបានបង្កើតឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងសម្រាប់ធ្វើការវាយតម្លៃភស្តុតាងសម្រាប់ការជំនុំជម្រះ គឺយោងតាមបទដ្ឋានអន្តរជាតិស្តីពីច្បាប់និងកិច្ចការពារសិទ្ធិ ក្នុងការទទួលបានការកាត់សេចក្តីដោយយុត្តិធម៌របស់ជនត្រូវចោទ។ ស្រដៀងគ្នានឹងឆន្ទានុសិទ្ធិដែលបានប្រគល់ឲ្យចៅក្រមនានានៅតុលាការអន្តរជាតិផ្សេងទៀតដែរ[២៨] អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញត្រូវបានប្រគល់ឲ្យនូវឆន្ទានុសិទ្ធិក្នុងការបដិសេធសំណើសុំផ្តល់ភស្តុតាង (ស្រដៀងគ្នានឹងការបដិសេធភស្តុតាងដែលបានបង្ហាញ) នៅពេលដែលភស្តុតាងបែបនេះ "មិនត្រូវបានអនុញ្ញាតតាមច្បាប់"[២៩]។ "ច្បាប់" ដែលអនុវត្តនៅកម្ពុជារួមបញ្ចូលទាំងច្បាប់អន្តរជាតិនានា ដូចជាអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មជាដើម[៣០]។

[២៧] ដើម្បីឲ្យបានយល់កាន់តែច្បាស់អំពីបទបញ្ញត្តិនៃវិធាន៨៧ នៃវិធានផ្ទៃក្នុង សូមមើល សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើភាពអាចទទួលយកសម្ភារៈនៅក្នុងសំណុំរឿងធ្វើជាភស្តុតាងបាន ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៩ ឯកសារ E43/4 កថាខណ្ឌទី៥ ដល់៧។

[២៨] វិធាន៩៥ នៃបទដ្ឋាននីតិវិធីនិងភស្តុតាងរបស់តុលាការ ICTY និង ICTR។

[២៩] វិធាន៨៧(៣)(ឃ) នៃវិធានផ្ទៃក្នុង។

[៣០] ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២។

00416862



២៨. អង្គបុរេជំនុំជម្រះសង្កេតឃើញថា កិច្ចដែលធ្វើដោយសហមេធាវីការពារក្ដី កំពុងស្នើសុំឲ្យមានការបដិសេធនូវភស្តុតាងដែលមានលក្ខណៈស្របនឹងមាត្រា១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ដែលចែងថា:

> "រដ្ឋជាភាគីនីមួយៗធានាថា ចម្លើយណាមួយដែលត្រូវបានបង្កើតឡើង ដោយសារការធ្វើទារុណកម្ម មិនត្រូវយកធ្វើជាភស្តុតាងនៅក្នុងកិច្ចដំណើរការនីតិវិធីណាមួយនោះទេ លើកលែងតែប្រឆាំងនឹងជនដែលជាប់ចោទពីបទធ្វើទារុណកម្ម ថាជាភស្តុតាងដែលគេបានធ្វើចម្លើយនោះ"។

២៩. នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់នៅក្នុងសេចក្ដីសម្រេចក្នុងរឿងក្ដីជនជាប់ចោទ កាំង ហ្គេកអ៊ាវ "ឌុច" ពាក់ព័ន្ធនឹងឯកសារនានាដែលបានមកដោយការធ្វើទារុណកម្មថា:

> "ឯកសារទាំងអស់នេះមានកំណត់ត្រឹមតែអង្គហេតុដែលថា ឯកសារទាំងនោះត្រូវបានបង្កើតឡើង និងក្នុងករណីសមស្របធ្វើជាភស្តុតាងបង្ហាញថា ឯកសារទាំងនោះត្រូវបានធ្វើឡើងដោយសារការធ្វើទារុណកម្ម។ ឯកសារទាំងនោះមិនត្រូវបានអនុញ្ញាតឲ្យយកមកប្រើប្រាស់ដើម្បីបញ្ជាក់ការពិតនោះទេ"[៣១]។

៣០. ថ្វីបើមានការសង្កេតដែលផ្ទុយគ្នាធ្វើដោយសហចៅក្រមស៊ើបអង្កេតនៅក្នុងដីកាក៏ដោយ[៣២] មាត្រា១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ត្រូវយកមកអនុវត្តយ៉ាងម៉ឺងម៉ាត់។ ពុំមានលទ្ធភាពសម្រាប់ការកំណត់អំពីការពិត ឬសម្រាប់ការប្រើប្រាស់ផ្សេងពីនេះ នូវចម្លើយណាមួយដែលបាន

[៣១] សូមមើលសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨ ដីកាលេខ E176 កថាខណ្ឌទី៤។

[៣២] ដីកា កថាខណ្ឌទី២៨។

មកតាមរយៈការធ្វើទារុណកម្មនោះទេ[៣៣]។ អង្គបុរេជំនុំជម្រះសង្កេតឃើញថា នៅពេលដែលអង្គបុរេជំនុំជម្រះបានទទួលបណ្តឹងឧទ្ធរណ៍នេះ សំណៅដើមនិងសំណៅដែលបានបកប្រែរួចចំនួនពីរច្បាប់នៃដីកា មិនមានភាពស៊ីសង្វាក់គ្នានោះទេ ជាពិសេសពាក់ព័ន្ធនឹងកថាខណ្ឌទី២៨[៣៤] ដែលបានលើកឡើងយ៉ាងពិសេស ក្នុងបណ្តឹងឧទ្ធរណ៍។ អង្គបុរេជំនុំជម្រះសង្កេតឃើញថែមទៀតថា ផ្អែកតាមភាពមិនស៊ីសង្វាក់គ្នានេះ ការអនុវត្តមាត្រា១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មពាក់ព័ន្ធនឹងភស្តុតាងបែបនេះ ដូចដែលបានពិភាក្សាគ្នានៅក្នុងដីកា មានភាពមិនច្បាស់លាស់នោះទេ។

៣១. អង្គបុរេជំនុំជម្រះយល់ឃើញថា សិទ្ធិរបស់ជនត្រូវចោទដែលបានចែងនៅក្នុងវិធាន២១ នៃវិធានផ្ទៃក្នុង ត្រូវបានការពារយ៉ាងពេញលេញ ដោយក្របខណ្ឌច្បាប់ដែលមានស្រាប់ ដូចបានលើកហេតុផលខាងលើ។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា វិធាន២១ នៃវិធានផ្ទៃក្នុងមិនបានដាក់កាតព្វកិច្ចឲ្យអង្គបុរេជំនុំជម្រះធ្វើការបកស្រាយវិធានផ្ទៃក្នុងថា បណ្តឹងឧទ្ធរណ៍គួរត្រូវបានប្រកាសថា អាចទទួលយកបាននោះទេ។

---

៣៣ ប្រវត្តិនៃការធ្វើសេចក្តីព្រាងនៃមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទា[illegible]មានភាពច្បាស់លាស់។ សូមមើលៈ ឯកសារអង្គការសហប្រជាជាតិ E/CN.4/1285 ចុះថ្ងៃទី១[illegible] ឆ្នាំ១៩៧៨។ សេចក្តីសង្ខេបដែលបានរៀបចំ ដោយ UN SG យោងតាមគណៈកម្មការ Res"n 18 (XXXIV) [illegible]សហប្រជាជាតិ E/CN.4/1314 ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៧៨។ គណៈកម្មការស្តីពីសិទ្ធិមនុស្ស សេចក្តីសម្រេច ១ (XXXVI) នៅកិច្ចប្រជុំលើកទី១៥២៦របស់ខ្លួន នៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ១៩៨០។ គណៈកម្មការស្តីពីសិទ្ធិមនុស្ស របាយការណ៍របស់ក្រុមការងារស្តីពីសេចក្តីព្រាងអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម និងការប្រព្រឹត្តិ ឬការដាក់ទណ្ឌកម្មដែលសាហាវព្រៃផ្សៃ អមនុស្សធម៌ ឬដែលថោកទាបផ្សេងទៀត E/CN.4/1367 ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ១៩៨០ កថាខណ្ឌទី៨២។ ត្រូវបានផលិតឡើងវិញនៅក្នុងគណៈកម្មការស្តីពីសិទ្ធិមនុស្ស របាយការណ៍ស្តីពីសម័យប្រជុំលើកទី៣៦ ពីថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ១៩៨០ ដល់ថ្ងៃទី១៤ ខែមីនា ឆ្នាំ១៩៨០ ឯកសារអង្គការសហ-ប្រជាជាតិ E/1980/13, E/CN.4/1408 កថាខណ្ឌទី២០៥ ទំព័រ៥២ ដល់៧៣ កថាខណ្ឌទី៨៣។

៣៤ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ចំណុចនេះត្រូវបានកែប្រែរួចហើយនៅក្នុង Zylab ប៉ុន្តែមិនទាន់បានកែប្រែនៅក្នុងគេហទំព័ររបស់អ.វ.ត.ក នៅឡើយទេ។

00416864

០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ២៦)

លេខ/N. D130/9/21

## ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេច ៖

បណ្តឹងឧទ្ធរណ៍មិនអាចទទួលយកបាន។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះបិទផ្លូវតវ៉ា។

ភ្នំពេញ ថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ២០០៨

**អង្គបុរេជំនុំជម្រះ** **ប្រធាន**

Rowan DOWNING **ន័យ ថុល** Katinka LAHUIS **ហួត វុទ្ធី** **ប្រាក់ គឹមសាន**